



(Traveling in Islam)

(Traveling in Islam)

~Traveling គួរធ្វើដោយមានគោលបំណង និងគោលដៅ

~Traveling ដើម្បីស្គាល់គ្នា និងយល់ដឹងពីគ្នាទៅវិញ ទៅមក

سورة الحجرات:13
ឱមនុស្សលោក! ពិតប្រាកដណាស់ យើងបានបង្កើតពួក អ្នកពីបុរសនិងស្ត្រី(អាដាំ និងហាវ៉ា) ហើយយើងធ្វើឱ្យពួកអ្នកមាន ជនជាតិ និងកុលសម្ព័ន្ធជាច្រើន ដើម្បីឱ្យពួកអ្នកស្គាល់គ្នាទៅវិញទៅ មក។

~Traveling ស៊ុណ្ណះធ្វើដំណើរដើម្បីស្វែងរកចំណេះវិជ្ជា
(Sunan Abi Dawud 3641)

~Traveling ស៊ុណ្ណះចេញដំណើរនៅថ្ងៃព្រហស្បតិ៍
(Riyad as-Salihin 956)

Caption

~Traveling ស៊ុណ្ណះចេញដំណើរ និងប្រកបរបរនៅពេល ព្រឹកព្រលឹម
(Riyad as-Salihin 957)

~Traveling ស៊ុណ្ណះត្រូវរួមដំណើរដោយមានគ្នីគ្នា មិនគួរ ធ្វើដំណើរម្នាក់ឯងនោះទេ
(Riyad as-Salihin 958)

~Traveling មិនគួរធ្វើដំណើរតែម្នាក់ឯងនៅពេលយប់នោះទេ

~Traveling ត្រូវធ្វើដំណើរមានគ្នីគ្នាចំនួន 3 នាក់

»តែម្នាក់ឯងមាន Satan ម្នាក់រួមដំណើរជាមួយ គាត់ ហើយអ្នកធ្វើដំណើរពីរនាក់នឹងមាន ស្យៃតនពីរនាក់រួម ដំណើរជាមួយ ហើយអ្នកដំណើរបីនាក់ គឺជាក្រុមមួយដែលអាចជួយគ្នា ទៅវិញទៅមក

(Riyad as-Salihin 959)

~Traveling ដែលមានចំនួន 4 នាក់គឺល្អបំផុត ឬវាជា ស៊ុណ្ណះមួយ

(Riyad as-Salihin 961)

~Traveling ត្រូវជ្រើសរើសមេដឹកនាំម្នាក់កំឡុង ពេលនោះ

(Riyad as-Salihin 960)

~Traveling ចូរធ្វើដំណើរនៅពេលយប់ ព្រោះថាដីត្រូវបានមូរនៅពេលយប់ គឺវាផ្តល់ភាព ងាយស្រួលនៅពេលឆ្លងកាត់អ្វីមួយ

(Riyad as-Salihin 964)

Caption

~Traveling ត្រូវឈប់សំរាកជាមួយការប្រមូលផ្តុំគ្នា ព្រោះថាការសំរាកដោយបែកខ្ញែក គ្នាវាជាទង្វើរបស់ Satan

(Riyad as-Salihin 965)

~Traveling មេដឹកនាំគួរនៅពីក្រោយគេ ដើម្បីដឹកនាំ និងជួយអ្នកទន់ខ្សោយ និងឲ្យ ពួកគេជិះលើជំនិះរបស់គាត់ និងបួងសួងសំរាប់ពួកគេផងដែរ

(Riyad as-Salihin 971)

~Traveling ការបួងសួងកំឡុងពេលនោះត្រូវបានគេទទួល យក

(Riyad as-Salihin 980)

~Traveling ជាផ្នែកមួយនៃទណ្ឌកម្ម ព្រោះវាបានរារាំងមនុស្សអំពីម្ហូបអាហារ ទឹក និងការដេក
(Riyad as-Salihin 984)

~Traveling ចូររួសរាន់វិលត្រឡប់ទៅរកគ្រួសាររបស់
ពួកគេវិញ បន្ទាប់ពីសំរេច បំណងរបស់ពួកគេក្នុងការធ្វើដំណើរនោះរួចហើយ

~Traveling គួរធ្វើដោយទឹកមុខញញឹមជានិច្ច

Narrated Ibn Jaz:
"I have not seen anyone who smiled more than the Messenger of Allah (ﷺ)."
(Jami` at-Tirmidhi 3641)

~Traveling មិនត្រូវយកគម្ពីរ al-Qur'an ទៅប្រទេសជា សត្រូវអីស្លាមនោះទេ

~Traveling មិនគួរទៅ និងត្រឡប់នៅផ្លូវតែមួយ

Caption

~Traveling ការសឡាតនៅលើជំនិះ កំឡុងពេលធ្វើដំណើរ ត្រូវបានអីស្លាមអនុញ្ញាតិ ប៉ុន្តែសំរាប់ សឡាតស៊ុណ្ណះប៉ុណ្ណោះ ។

~Traveling អ្នកដទៃក៏អាចធ្វើការបួងសួងសំរាប់យើងផងដែរដូចជាសូត្រថា៖

" أَسْتَوْدِعُ اللهَ دِينَكَ ، وَأَمَانَتَكَ ، وَخَوَاتِيمَ عَمَلِكَ"

~Traveling រ៉ស៊ូលុលឡោះ ﷺ តែងតែចូលតាមផ្លូវខ្ពស់ និងចេញមកវិញតាមផ្លូវទាប

រ៉សូលុលឡោះ ﷺ តែងតែ ចេញអំពីទីក្រុងម៉ាទីណះតាមផ្លូវអាស្សាហ្ជារ៉ោះ និងចូលម៉ាទីណះវិញតាម ផ្លូវអាល់មូអារ៉ស់ ហើយនៅពេលលោកចូលទីក្រុងម៉ក្កះ លោកចូលតាមផ្លូវខ្ពស់ និងចេញមកវិញតាមផ្លូវទាប(តាមជ្រលងភ្នំ)។

(រាយការណ៍ដោយអាល់ពូខរី និងមូស្លីម)

(Riyad as-Salihin 720)

~រ៉សូលុលឡោះ ﷺ តែងតែដើរផ្លូវខុសគ្នាពេលចេញទៅសឡាត និងពេលត្រឡប់មកវិញ

(Riyad as-Salihin 719)

•សីលធម៌ក្នុងការធ្វើដំណើរ

~Traveling ការឈប់ ការស្នាក់នៅ ការសំចត ការឈប់សំរាកនៅពេលយប់ ការដេកកំឡុងពេលធ្វើដំណើរ អ្នករួមដំណើរ ត្រូវប្រព្រឹត្តទៅដោយ៖

1.ធ្វើរដំណើរកាត់វាលស្មៅត្រូវផ្តល់ចំណីឲ្យសត្វ

2.ធ្វើរដំណើរកាត់ដីហួតហែងត្រូវបង្កើនល្បឿនស្របពេលដែលជំនិះនៅមានកំលាំង

3.ហាមចុះសំរាកនៅលើផ្លូវ ព្រោះវាជាផ្លូវរបស់សត្វពាហនៈ និងជាកន្លែងស្នាក់នៅរបស់សត្វល្អិតនៅពេលយប់

4.ការដេកកំឡុងពេលធ្វើរដំណើរត្រូវដេកផ្អៀងទៅ ខាងស្តាំ ហើយនៅពេលបានសំរាកបន្តិច ឬមុនពេលស៊ូពោះ(ពេលសេតារុណរះ) ត្រូវបត់ដៃស្តាំ ហើយដាក់ក្បាលលើបាតដៃ។

5.ចុះសំរាកដោយប្រមូលផ្តុំគ្នាជាក្រុម

6.ចុះសំរាកដោយរៀបចំដោះពន្លត់ជំនិះជាមុនទើបធ្វើអ្វីផ្សេង បន្ទាប់ពីនោះ

7.ជ្រើសរើសជំនិះដែលសាកសមដែលមានសមត្ថភាពអាចធ្វើដំណើរបាន

8.អ្នកមានជំនិះលើសពីតម្រូវការគួរផ្តល់ឲ្យអ្នកគ្មានជំនិះ

(អ្នករួមដំណើរជាមួយ)

9.គួរផ្លាស់ប្តូរវេនគ្នាជិះជំនិះ

(អ្នករួមដំណើរជាមួយដែលជាសាច់ញ្ញៀត)

10.អ្នកដឹកនាំគួរនៅពីក្រោយគេក្នុងពេលធ្វើដំណើរ

11.កុំត្រឡប់មករកគ្រួសារវិញនៅពេលយប់ (ឬបើជននោះអវត្តមានពីក្រុមគ្រួសារយូរថ្ងៃ)

12.ចូរត្រឡប់ទៅគ្រួសារវិញនៅពេលព្រឹក ឬពេលល្ងាច

13.ចូរសឡាតពីររ៉ក្អាត់នៅម៉ាស្ជិតបន្ទាប់ពីត្រឡប់ពីធ្វើដំណើររួច

14.ស្ត្រីមិនអនុញ្ញាតិធ្វើដំណើរម្នាក់ឯងដោយគ្មានម៉ះរ៉ុំ(ប្តី ឬសាច់ញ្ញាតដែលច្បាប់អ៊ីស្លាម មិនអនុញ្ញាតអោយរៀបការជាមួយ) ឬចំងាយដំណើរមួយថ្ងៃមួយយប់សូម្បីតែប្តីបាន ចុះឈ្មោះទៅធ្វើសង្គ្រាមរួចរាល់ហើយក៏ត្រូវបោះបង់និងរួម ដំណើរជាមួយប្រពន្ធរបស់ខ្លួនវិញ

15.ចូរធ្វើដំណើរដោយកាយវិការសុភាពរាបសា

Caption

وَعِبَادُ الرَّحْمَنِ الَّذِينَ يَمْشُونَ عَلَى الْأَرْضِ هَوْنًا وَإِذَا خَاطَبَهُمُ الْجَاهِلُونَ قَالُوا سَلَامًا
سورة الفرقان:63

ហើយបណ្តាខ្ញុំ(ដែលល្អត្រឹមត្រូវ)នៃម្ចាស់មហាសប្បុរស គឺជាពួកដែលធ្វើដំណើរនៅលើផែនដីដោយកាយវិការសុភាពរាបសា ហើយនៅពេលដែលពួកល្ងង់ខ្លៅនិយាយ(ពាក្យអសុរស)ទៅ កាន់ពួកគេ ពួកគេបានតបវិញនូវពាក្យសំដីទន់ភ្លន់សុភាពរាបសា។

(Riyad as-Salihin 962, 963, 964, 966, 968, 969, 970, 971, 985, 986, 988, 990)

•បួងសួងពេលធ្វើដំណើរ ឡើងជំនិះ ជួបគ្រោះភ័យ ពេលត្រឡប់មកវិញ

~អល់ឡោះបានមានបន្ទូលថា : " ទ្រង់បានបង្កើតអោយពួកអ្នកនូវនាវា និងសត្វ ពាហនៈ ដែលពួកអ្នកជិះ គឺដើម្បីអោយពួកអ្នកបានឡើងលើខ្នងរបស់វា និងថ្លែង អំណរគុណចំពោះឧបការគុណម្ចាស់របស់ពួកអ្នក នៅពេលដែលពួកអ្នកនៅលើ ខ្នងរបស់វា និងសូត្រថា:

" سُبْحَانَ الَّذِي سَخَّرَ لَنَا هَذَا وَمَا كُنَّا لَهُ مُقْرِنِينَ * وَإِنَّا إِلَى رَبِّنَا لَمُنْقَلِبُونَ "

"មហាបរិសុទ្ធ ទ្រង់ដែលបានសំរួលដល់ពួកយើង ពួកយើងគ្មានលទ្ធភាពចំពោះ វាឡើយ។ ការពិតពួកយើងនឹងត្រូវវិលត្រឡប់ទៅចំពោះម្ចាស់របស់យើង"។ (អាហ្សូខរូហ្វ: ១២-១៥)

~បួងសួងផ្សេងទៀតថា៖

អំពី អ៊ីបនូអ៊ូមើរ رضي الله عنهما ថា : ពិតណាស់ រ៉សូលុលឡោះ ﷺនៅ ពេលឡើងលើខ្នងសត្វអូដ្ឋរបស់លោក លោកបានសូត្រតឹកពៀរ(អល់ឡោហ៊ូ អឹក ពើរ)ចំនួនបីដង បន្ទាប់មក លោកសូត្រថា:

سبْحانَ الذي سخَّرَ لَنَا هذا وما كنَّا له مُقرنينَ، وَإِنَّا إِلى ربِّنَا لَمُنقَلِبُونَ . اللَّهُمَّ إِنَّا نَسْأَلُكَ في» : سَفَرِنَا هذا البرَّ والتَّقوى ، ومِنَ العَمَلِ ما تَرْضى . اللَّهُمَّ هَوِّنْ علَيْنا سفرَنَا هذا وَاطوِ عنَّا بُعْدَهُ ، اللَّهُمَّ أَنتَ الصَّاحِبُ في السَّفرِ ، وَالخَلِيفَةُ في الأهْلِ. اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنْ وعْثَاءِ السَّفرِ ، وكَآبَةِ المنظَرِ ، وَسُوءِ المنْقَلَبِ في المالِ والأهلِ وَالوَلَدِ «

"មហាបរិសុទ្ធ ទ្រង់ដែលបានសំរួលដល់ពួកយើងនេះ ពួកយើងគ្មានលទ្ធភាព ចំពោះវាឡើយ។ ការពិតពួកយើងនឹងត្រូវវិលត្រឡប់ទៅចំពោះម្ចាស់របស់យើង។ ឱអល់ឡោះ! ពិតណាស់ ពួកយើងសុំពីទ្រង់ ក្នុងការធ្វើដំណើររបស់ពួកយើងនេះ នូវ ទង្វើកុសល ការកោតខ្លាចទ្រង់ និងទង្វើដែលទ្រង់ពេញចិត្ត។ ឱអល់ឡោះ! សូមទ្រង់សំរួលដល់ពួកយើង

ឱអល់ឡោះ! សូមទ្រង់សំរួលដល់ពួកយើង នូវការធ្វើដំណើររបស់ពួកយើងនេះ និងបំព្រួញចម្ងាយ របស់វាអោយពួកយើងផង។ ឱអល់ឡោះ! ទ្រង់គឺជាអ្នកនៅជាមួយពួកយើង(ទ្រង់ ឃើញ ទ្រង់ដឹង លឺ)ក្នុងពេលធ្វើដំណើរ និងជាអ្នកថែរក្សាគ្រួសាររបស់ពួកយើង។ ឱ អល់ឡោះ! ពិតណាស់ ខ្ញុំសុំពីទ្រង់មេត្តាបញ្ចៀសខ្ញុំពីការលំបាកក្នុងការធ្វើដំណើរ រូបភាពទុក្ខព្រួយនានា និងការវិលត្រឡប់ដ៏អាក្រក់ចំពោះគ្រួសារ ទ្រព្យសម្បត្តិ និងកូនចៅ" នៅពេលវិលត្រឡប់ពីការធ្វើដំណើរវិញ លោកសូត្រដដែល និង បន្ថែមថា:

" آيِبُونَ ، تَائِبُونَ ، عَابِدُونَ ، لِرَبِّنَا حَامِدُونَ "

" ពួកយើងវិលត្រឡប់វិញ ដោយសារភាពកំហុសទៅចំពោះទ្រង់ គោរពសក្ការៈទៅចំពោះទ្រង់ និងកោតសរសើរទៅចំពោះទ្រង់" (រាយការណ៍ដោយ មូស្លីម)
(Riyad as-Salihin 972)

~បួងសួងផ្សេងទៀតថា៖

اللهم أني اعوذ بك مِن وعْثاءِ السفَرِ ، وكآبَةِ الْمُنْقَلَبِ ، والحوْرِ بعْد الكَوْنِ ، ودعْوةِ المظلُومِ . وسوءِ المنْظَرِ في الأهْلِ والمَالِ . رواه مسلم .

Caption

អំពី អាប់ទុលឡោះ ពិន សើរជីស رضي الله عنه ថា : រ៉ស៊ូលុលឡោះ ﷺ នៅពេលធ្វើដំណើរ លោកបានសុំពីអល់ឡោះ បញ្ចៀសអំពី ការលំបាកក្នុងពេលធ្វើដំណើរ ទុក្ខព្រួយពេលវិលត្រឡប់ ការធ្លាក់ចុះបន្ទាប់ពីបានខ្ពង់ខ្ពស់ ការបួងសួងរបស់អ្នក ដែលត្រូវគេបំពាន និងរូបភាពអាក្រក់នានាចំពោះគ្រួសារ និងទ្រព្យសម្បត្តិ"
(រាយការណ៍ដោយមូស្លីម)
(Riyad as-Salihin 973)

~ឬសូត្រតាមរបៀបនេះថា៖

»នៅពេលដាក់ជើងលើជំនិះសូត្រថា: بِسْمِ الله

»នៅពេលឡើងអង្គុយលើខ្នងរបស់សត្វ ឬចូលក្នុងជំនិះសូត្រថា: الحَمْدُ لِله

»បន្ទាប់មកសូត្រចំនួន 3 ដងថា៖

"سُبْحَانَ الَّذِي سَخَّرَ لَنَا هَذَا وَمَا كُنَّا لَهُ مُقْرِنِينَ
* وَإِنَّا إِلَى رَبِّنَا لَمُنْقَلِبُونَ "

»បន្ទាប់មកទៀត លោកបួងសួង ថា:
"سُبْحَانَكَ إنّي ظَلَمْتُ نَفْسِي فَاغْفِرْ لِي فَإِنَّهُ لا يَغْفِرُ الذُّنُوبَ إلا أَنْتَ"
"ទ្រង់ដ៏មហាបរិសុទ្ធ ខ្ញុំពិតជាបានបំពានចំពោះខ្លួនឯង ហេតុនេះសូមទ្រង់អភ័យ ទោសដល់ខ្ញុំផង ព្រោះគ្មានអ្នកណាអាចអភ័យទោសអោយខ្ញុំក្រៅអំពីទ្រង់ឡើយ"
(Riyad as-Salihin 974)

~បួងសួងនៅពេលឡើងទីកន្លែងខ្ពស់ ឬភ្នំតូចៗ

»សូត្រថា: اَللهُ أَكْبَرُ ចំនួនបីដង

»បន្ទាប់មកសូត្រថា:

" لا إلَهَ إلا اللهُ وَحْدَهُ لا شَرِيكَ لَهُ ، لَهُ المُلْكُ وَلَهُ الحَمْدُ ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ . آيِبُونَ ، تَائِبُونَ ، عَابِدُونَ ، سَاجِدُونَ، لِرَبِّنَا حَامِدُونَ ، صَدَقَ اللهُ وَعْدَهُ ، وَنَصَرَ عَبْدَهُ ، وَهَزَمَ الأَحْزَابَ وَحْدَهُ "

»ឬសូត្រថា៖

"لا إلَهَ إلا اللهُ اَللهُ أَكْبَرُ "
(គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវមានតែអល់ឡោះ អល់ឡោះ មហាធំធេងបំផុត)

»នៅពេលចុះទីកន្លែងទាបសូត្រថាៈ سُبْحَانَ الله (អល់ឡោះ ដ៏មហា បរិសុទ្ធ)។
(រាយការណ៍ដោយអាពូដាវូទ ដោយមានបង្អែកត្រឹមត្រូវ)
(Riyad as-Salihin 977)

~បួងសួងនៅពេលធ្វើដំណើរជួបក្រុមមនុស្សដែលគួរឲ្យភ័យខ្លាច ឬមានការភ័យខ្លាច

" اللَّهُمَّ إنَّا نَجْعَلُكَ في نُحُورِهِمْ ، وَنَعُوذُ بِكَ مِنْ شُرُورِهِمْ "
(ឱអល់ឡោះ! ពួកយើងសុំពីទ្រង់អោយប្រឈមមុខនឹងពួកគេ ហើយពួកយើង សុំពីទ្រង់ បញ្ចៀសពួកយើង ពីប្រការអាក្រក់របស់ពួកគេ"
(រាយការណ៍ដោយអាពូដាវូទ និងអាន់ណាសាអ៊ី ដោយមានបង្អែកត្រឹមត្រូវ)
(Riyad as-Salihin 981)

~បួងសួងនៅពេលសំរាកនៅកន្លែងណាមួយ ឬចូលក្នុងតំបន់ របស់អ្នកដទៃត្រូវសូត្រថាៈ

" أَعُوذُ بِكَلِمَاتِ اللهِ التَّامَّاتِ مِنْ شَرِّ مَا خَلَقَ "

(ខ្ញុំសុំតាមរយៈ ពាក្យ ពេចន៍ដ៏ពេញលេញរបស់អល់ឡោះ អោយទ្រង់បញ្ចៀសខ្ញុំ អំពី ប្រការអាក្រក់ ដែលទ្រង់បានបង្កើត)នោះ គ្មានអ្វីអាចបង្កគ្រោះថ្នាក់ដល់គាត់ឡើយ រហូតដល់ គាត់ចេញដំណើរពីកន្លែងឈប់របស់គាត់នោះ។ (រាយការណ៍ដោយមូស្លីម)
(Riyad as-Salihin 982)

~បួងសួងកំឡុងពេលធ្វើដំណើរនៅពេលយប់ត្រូវសូត្រថាៈ

" يَا أَرْضُ، رَبِّي وَرَبُّكِ اللهُ ، أَعُوذُ بِاللهِ مِنْ شَرِّكِ وَشَرِّ مَا فِيكِ ، وَشَرِّ مَا خُلِقَ فِيكِ ، وَشَرِّ مَا يَدِبُّ عَلَيْكِ ، أَعُوذُ بِاللهِ مِنْ شَرِّ أَسَدٍ وَأَسْوَدٍ ، وَمِنَ الحَيَّةِ وَالعَقْرَبِ ، وَمِنْ سَاكِنِ البَلَدِ ، وَمِنْ وَالِدٍ وَمَا وَلَدَ "

("ដឺ! ម្ចាស់របស់ខ្ញុំនិងម្ចាស់របស់អ្នកគឺអល់ឡោះ! ខ្ញុំសុំអំពីអល់ឡោះអោយ បញ្ចៀសខ្ញុំពីប្រការអាក្រក់របស់អ្នក និងអ្វីដែលនៅលើអ្នក និងប្រការអាក្រក់ ដែលគេបង្កើតនៅក្នុងអ្នក និងប្រការអាក្រក់នៃអ្វីៗដែលដើរលើអ្នក។ ហើយខ្ញុំ សុំពីអល់ឡោះបញ្ចៀសខ្ញុំអំពី សត្វតោ ពស់ខ្មៅ ពស់គ្រប់ប្រភេទ សត្វខ្ទួយ អ្នកនៅក្នុងស្រុក(បិសាច) ពីឪពុករបស់វា(អ៊ីព្លេស) និងកូនចៅរបស់វា (បិសាច ស្បៃតន)។ (រាយការណ៍ដោយអាពូដាវូទ)
(Riyad as-Salihin 983)

~បួងសួងនៅពេលឃើញភូមិស្រុករបស់យើង (ត្រឡប់មកពីធ្វើដំណើរ) និងត្រូវសូត្ររហូតដល់ច្រកទ្វា៖

"آيِبُونَ ، تَائِبُونَ ، عَابِدُونَ ، سَاجِدُونَ ، لِرَبِّنَا حَامِدُونَ"

(ពួកយើងជាអ្នកវិលត្រឡប់វិញ ជាអ្នកសារភាពកំហុស គោរពសក្ការៈនិង អោន ស៊ូជោតទៅចំពោះទ្រង់។រាល់ការសរសើរទាំងឡាយ គឺសំរាប់ម្ចាស់របស់ ពួកយើង)
(Riyad as-Salihin 987)

Caption

~បួងសួងសំរាប់អ្នកដទៃថា៖

« اللَّهمَّ اطْوِ لهُ البُعْدَ ، وَهَوِّنْ عَليهِ السَّفر»

"ឱអល់ឡោះ! សូមទ្រង់បំព្រួញចម្ងាយសំរាប់គាត់ និងសំរួលដល់ការធ្វើដំណើររបស់គាត់"
 (រាយការណ៍ដោយអាត់តៀរមីត្សុី ហើយគាត់ និយាយថា ហាទីស្ហនេះល្អ)
(Riyad as-Salihin 978)

»ឬសូត្រថា៖

"أَسْتَوْدِعُ اللهَ دِينَكَ ، وَأَمَانَتَكَ ، وَخَوَاتِيمَ عَمَلِكَ"

ខ្ញុំសូមផ្ទុកផ្តាក់នឹងអល់ឡោះចំពោះសាសនារបស់អ្នក ភាពទៀងត្រង់របស់អ្នក និងទង្វើចុងក្រោយរបស់អ្នក"។ (រាយការណ៍ដោយអាត់តៀរមីត្ស៊ី ហើយគាត់ និយាយថា: ហាទីសហនេះល្អត្រឹមត្រូវ)

(Riyad as-Salihin 715)

»ឬសូត្រថា៖

>زَوَّدَكَ اللَّهُ التَّقْوَى " សូមអល់ឡោះបន្ថែមនូវ សេចក្តីកោតខ្លាចចំពោះទ្រង់ដល់អ្នក"

>និង « وَغَفَرَ ذَنْبَكَ » " សូមអល់ឡោះ អភ័យ ទោសដល់អ្នក"

>និង « وَيَسَّرَ لَكَ الْخَيْرَ حَيْثُمَا كُنْتَ» " សូមទ្រង់សម្រួលនូវប្រការល្អដល់អ្នកទោះបី អ្នកនៅទីកន្លែងណាក៏ដោយ"

(Riyad as-Salihin 717)

Caption